# ក្របខ័ណ្ឌប្រតិបត្តិការ

## ក្រុមការងារបច្ចេកទេសចំរុះរវាង
## រាជរដ្ឋាភិបាលកម្ពុជា និង ប្រទេសផ្តល់ជំនួយ ស្តីពីកសិកម្ម និងទឹក

*ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៤*


**១ សាវតា** ..........២

**២ អាណត្តិ និងវិសាលភាព** ..........៤

**៣ គោលបំណង និងមុខងារ** ..........៦

**៤ អង្គការចាត់តាំង និងប្រតិបត្តិការ** ..........៨

**៤.១** សមាជិកភាព ..........៩

**៤.២** អធិបតី ..........១០

**៤.៣** លេខាធិការដ្ឋាន ..........១១

**៤.៤** អនុក្រុមទទួលបន្ទុកបញ្ហាជាក់លាក់ ..........១២

**៤.៥** កិច្ចប្រជុំ ..........១២

**៤.៦** ទំនាក់ទំនងជាមួយនឹងក្រុមការងារផ្សេងៗទៀត កិច្ចប្រជុំក្រុមពិគ្រោះយោបល់ និងការពិភាក្សាអំពីគោលនយោបាយផ្សេងៗទៀត ..........១២

**៤.៧** តារាងរចនាសម្ព័ន្ធ ..........១៣

## ១ សាវតា

១. គោលដៅអភិវឌ្ឍន៍ចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រ ។ ជាលក្ខណៈសេដ្ឋកិច្ច គោលដៅនេះបង្ហាញពីលំនាំនៃកំណើនមួយ ដែលមានលក្ខណៈទូលំទូលាយ និងផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្រីក្រ ។ វិស័យកសិកម្មមានតួនាទីមួយដ៏សំខាន់នៅក្នុងគោលដៅនេះ ដោយសារតែប្រជាជនភាគច្រើន និង ជាពិសេសប្រជាជនក្រីក្ររស់នៅទីជនបទពឹងផ្អែកទៅលើវិស័យកសិកម្មនេះ ។ ហេតុដូចនេះ បញ្ហាប្រឈមដ៏សំខាន់ គឺការសំរេចឱ្យបាននូវការលូតលាស់ខាងវិស័យកសិកម្មប្រកបដោយនិរន្តរភាពខ្ពស់ និងការផ្សារភ្ជាប់ប្រជាជនក្រីក្រទៅនឹងការលូតលាស់នេះ ។ ក្នុងខណៈដែលភាពស្វ័យគ្រប់គ្រាន់ជាមូលដ្ឋាន (basic self-sufficiency) នៅក្នុងផលិតកម្មស្បៀងត្រូវបានសំរេចកាលពីអតីតកាល វិស័យកសិកម្មឥឡូវនេះកំពុងស្ថិតនៅផ្លូវបំបែកមួយ ដែលការរួមវិភាគទានរបស់វិស័យនេះដើម្បីធ្វើអោយកំរិតជីវភាពរស់នៅបានប្រសើរឡើងយ៉ាងទូលំទូលាយនៅទីជនបទនោះ តំរូវអោយមានការកើនឡើងនូវផលិតភាពអោយកាន់តែបានច្រើនឡើង ( *ក្នុងចំណោមវិស័យដទៃទៀតដើម្បីធានាឱ្យមានសន្តិសុខស្បៀងនៅកំរិតគ្រួសារ*) ក៏ដូចជាការបង្កើននូវពិពិធកម្ម (diversification) និងពាណិជ្ជភាវូបនីយកម្ម ឱ្យកាន់តែទូលំទូលាយថែមទៀត ។ ការធានាអោយមានលទ្ធភាពទទួលបានដីធ្លី មធ្យោបាយផលិតកម្មដែលមានគុណភាពខ្ពស់ ការធ្វើអោយប្រសើរឡើងនូវការកែច្នៃក្រោយពេលប្រមូលផល គមនាគមន៍សំរាប់ប្រតិបត្តិការ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការបង្កើតអង្គការសង្គមថ្មីៗសំរាប់ផលិតកម្ម និងទីផ្សារ (ឧទាហរណ៍: សមាគមកសិករ បណ្តុំអាគារកសិឧស្សាហកម្ម និងការចាត់ចែងកិច្ចសន្យាកសិកម្មនានាជាដើម) បន្ថែមទៅលើបរិយាកាសខាងរដ្ឋបាល និង នយោបាយមួយប្រកបដោយភាពអនុគ្រោះនោះ គឺជាកត្តាសំខាន់ៗនៅក្នុងដំណើរការនេះ។ នៅក្នុងការវិភាគចុងក្រោយ អ្វីដែលជាតំរូវការនោះមានទំហំហួសពីទស្សនៈវិស័យដែលផ្តោតលើផលិតកម្មតែមួយមុខ ឬវិស័យតែមួយទៅទៀត។ ដោយជំនួសវិញនោះ ការគាំទ្រការអភិវឌ្ឍន៍វិស័យកសិកម្មត្រូវការអោយមាននូវទស្សនៈអភិវឌ្ឍន៍ជនបទដ៏ទូលំទូលាយមួយ ។

២. រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់អំពីសារៈសំខាន់នៃវិស័យកសិកម្មនេះ ដូចដែលបានចែងនៅក្នុងឯកសារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី ២ ឆ្នាំ ២០០១-២០០៥ និង យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០៣-២០០៥ និងថ្មីៗនេះ គឺយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ឆ្នាំ ២០០៤-២០០៨ ជាដើម ។ ការលើកស្ទួយការអភិវឌ្ឍន៍វិស័យកសិកម្ម គឺជាផ្នែកជាអាទិភាពមួយ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយភាពក្រីក្រ ។ ក៏ប៉ុន្តែ នៅក្នុងពេលជាមួយគ្នានេះ វិស័យកសិកម្ម គឺជាវិស័យមួយក្នុងចំណោមវិស័យសំខាន់ៗមួយចំនួនតូច ដែលខ្វះនូវយុទ្ធសាស្ត្រទូលំទូលាយមួយសំរាប់វិស័យ ដែលទាក់ទងនឹងគោលដៅធំៗទាំងឡាយដែលបានបញ្ជាក់យ៉ាងជាក់លាក់នៅក្នុងឯកសារទាំងនេះ។ លើសពីនេះទៅទៀត ការអនុវត្តន៍យុទ្ធសាស្ត្រនេះ តំរូវអោយមានការបញ្ចូលបញ្ហាវិមជ្ឈការក្នុងវិស័យ និង នីតិវិធីធ្វើផែនការ ដោយតម្រូវទៅតាមក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលនឹងបង្កើតបានជាវិធីសាស្ត្រធ្វើផែនការ និងគំរោងថវិការួមរបស់រាជរដ្ឋាភិបាល ។

៣. ដំណើរការ និងឯកសារទាំងឡាយខាងលើនេះ រួមជាមួយនឹងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ជាតំណាងនូវវេទិកានៃការពិភាក្សាកំរិតខ្ពស់អំពីគោលនយោបាយរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមប្រទេសផ្តល់ជំនួយ ។ រហូតដល់ដើមឆ្នាំ ២០០៣ ក្រុមការងាររបស់ប្រទេសផ្តល់ជំនួយស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ដែលបានបង្កើតឡើងជាក្រុមការងារមួយ ក្នុងចំណោមក្រុមការងារទាំង ៥ ដើម្បីតាមដានត្រួតពិនិត្យមើល និងធ្វើការកែលំអផលប៉ះពាល់នៃការពិភាក្សាអំពីគោលនយោបាយស្តីពីសូចនាករអភិវឌ្ឍន៍ជាក់ស្តែងនោះ គឺជាវេទិកាដែលត្រូវបានកំណត់ទុក សំរាប់ការពិភាក្សាអំពីប្រធានបទទាំងឡាយដែលទាក់ទងនឹងវិស័យកសិកម្ម ។ តែតាមការជាក់ស្តែង វេទិកានេះបានផ្តោតការយកចិត្តទុកដាក់ភាគច្រើនតែទៅលើបញ្ហាព្រៃឈើទៅវិញទេ ។ ជាងនេះទៅទៀត ក្រុមការងាររបស់ប្រទេសផ្តល់ជំនួយស្តីពីការគ្រប់គ្រងធនធានធម្មជាតិនេះ បានលើកឡើងនូវបញ្ហាទាំងឡាយក្នុងកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមប្រទេសផ្តល់ជំនួយនៅកំរិតមួយខ្ពស់ជាបង្គួរ ។ កាលពីចុងឆ្នាំ ២០០២ ក្រុមប្រទេសផ្តល់ជំនួយដែលពាក់ព័ន្ធនៅក្នុងក្រុមការងារស្តីពីការគ្រប់គ្រងធនធានធម្មជាតិនេះ បានស្នើសុំអោយបង្កើតឡើងនូវក្រុមការងារថ្នាក់បច្ចេកទេសមួយចំនួនជំនួសវិញ ដើម្បីសំរបសំរួលការងារកិច្ចសហប្រតិបត្តិការ និងការងារសំរបសំរួលគ្នាអោយកាន់តែប្រសើរឡើងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមប្រទេសផ្តល់ជំនួយ ។ ជាពិសេសគេបានស្នើសុំអោយបង្កើតឡើងនូវក្រុមការងារបច្ចេកទេសទាំងឡាយសំរាប់ការគ្រប់គ្រងដីធ្លី កសិកម្ម និងសន្តិសុខស្បៀង ទឹក នេសាទ និងព្រៃឈើ ។

៤. នៅក្នុងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីធ្វើអោយកិច្ចសហការគ្នាបានប្រសើរឡើង និងដើម្បីចៀសវាងការមានក្រុមការងារចំនួនច្រើនពេក ក្រុមប្រទេសផ្តល់ជំនួយដែលពាក់ព័ន្ធនៅក្នុងវិស័យទឹក បានសំណូមពរអោយមានការបញ្ចូលគ្នានូវក្រុមការងារកសិកម្ម និងក្រុមការងារទឹក ដែលបានស្នើឡើងនោះ ដោយយល់ឃើញថា ការធ្វើដូច្នេះនឹងកំរិតវិសាលភាពតែវិស័យទឹកដែលមានការទាក់ទងជាមួយនឹងកសិកម្មតែប៉ុណ្ណោះ ។ ទាក់ទងជាមួយនឹងបញ្ហាសន្តិសុខ ស្បៀង គេបានទទួលស្គាល់ថា វេទិកាមួយបានកើតមានរួចស្រេចហើយ គឺវេទិកាសន្តិសុខស្បៀង ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទនិងវិស័យកសិកម្ម និងកម្មវិធីស្បៀងអាហារពិភពលោក បានធ្វើជាសហប្រធានដឹកនាំ ។ ក្នុងខណៈដែលគេបានទទួលស្គាល់ថា ក្រុមការងារផ្នែកកសិកម្មនឹងចាំបាច់ត្រូវតែលើកឡើងអំពីបញ្ហាសន្តិសុខស្បៀង ការផ្តោតការយកចិត្តទុកដាក់របស់ក្រុមនេះ គឺនឹងមានលក្ខណៈទូទៅច្រើនជាង ។

៥. កាលពីខែកញ្ញា ឆ្នាំ ២០០៣ កិច្ចព្រមព្រៀងមួយត្រូវបានសំរេចឡើងដើម្បីបង្កើតនូវក្រុមការងារថ្នាក់បច្ចេកទេសរួមរវាងរាជរដ្ឋាភិបាលកម្ពុជានិងប្រទេសផ្តល់ជំនួយ សំរាប់វិស័យកសិកម្ម និង ទឹក *(ដែលទាក់ទងនឹងវិស័យកសិកម្ម)* ដែលនឹងផ្តល់នូវវេទិកាមួយ សំរាប់ក្រុមអ្នកចូលរួមទាំងអស់ដែលមានការចាប់អារម្មណ៍ លើវិស័យនេះរួមគ្នាធ្វើការដើម្បីជំរុញការអភិវឌ្ឍន៍វិស័យកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦. គំនិតនៃក្រុមការងារបច្ចេកទេសមួយសំរាប់វិស័យកសិកម្មនេះត្រូវបានបង្កើតឡើង មួយផ្នែកសំរាប់ជាឧបករណ៍គាំទ្រមួយសំរាប់កិច្ចពិភាក្សាថ្នាក់ខ្ពស់រវាងរាជរដ្ឋាភិបាលកម្ពុជានិងក្រុមប្រទេសផ្តល់ជំនួយ ។ ក៏ប៉ុន្តែនៅ

ក្នុងពេលជាមួយគ្នានេះ សេចក្តីត្រូវការឱ្យមានក្រុមការងារមួយនេះ អាចត្រូវបានផ្អែកទៅលើតំរូវការយ៉ាងជាក់ស្តែង សំរាប់វិស័យនេះផងដែរ ។ សកម្មភាពទាំងឡាយរបស់ក្រុមប្រទេសផ្តល់ជំនួយ គឺគាំទ្រព្រះរាជាណាចក្រកម្ពុជា នៅក្នុងការកែលំអការអនុវត្តនីការងាររបស់វិស័យកសិកម្មនេះ ។ សកម្មភាពទាំងនេះលើកឡើងនៅកំរិតផ្សេងៗ ចាប់ពីថ្នាក់ជាតិ ចុះទៅដល់ថ្នាក់ស្រុក និងថ្នាក់ភូមិ និងតំបន់ភូមិសាស្ត្រនានា ។ ជាក់ស្តែង ការធ្វើអោយវិស័យកសិកម្មនេះ ក្លាយទៅជាកំលាំងជំរុញមួយសំរាប់កំណើនសេដ្ឋកិច្ចដែលផ្តល់ផលប្រយោជន៏ដល់ប្រជាជនក្រីក្រ តំរូវឱ្យមានទស្សនៈវិស័យរួមមួយដែលផ្តល់ការតំរង់ទិស និង លើកកំពស់ប្រសិទ្ធភាពរបស់គំរោងទាំងនោះ។ ផែនទីវិធីឬយុទ្ធសាស្ត្រសំរាប់វិស័យមួយ ដែលជាកម្មសិទ្ធិ និងគ្រប់គ្រងដោយអង្គភាពទាំងឡាយរបស់រដ្ឋាភិបាល នឹងផ្តល់នូវទស្សនៈវិស័យដូចនេះ ហើយក្រុមការងាររួមរវាងរដ្ឋាភិបាល និងក្រុមប្រទេសផ្តល់ជំនួយ អាចនឹងជាឧបករណ៏ជំរុញនៅក្នុងការសំរបសំរួលដល់ការបង្កើតឡើងនូវយុទ្ធសាស្ត្រនេះ និងប្រែក្លាយយុទ្ធសាស្ត្រនេះទៅជាយន្តការតំរង់ទិសសំរាប់វិស័យមួយ ដែលអាចធ្វើអោយកិច្ចប្រឹងប្រែងផ្សេងៗស៊ីសង្វាក់គ្នា ។

៧. បន្ទាប់ពីមានកិច្ចប្រជុំត្រៀមក្រៅផ្លូវការមួយចំនួនមក ឯកសារនេះបានផ្តល់នូវអនុសាសន៏ទាំងឡាយស្តីពីអាណត្តិ គោលបំណង អង្គការចាត់តាំង និងទំនាក់ទំនងជាមួយនឹងវេទិកាពិភាក្សាគ្នាផ្សេងៗទៀតរបស់ក្រុមការងារនេះ ។

## ២ អាណត្តិ និងវិសាលភាព

៨. ក្រុមការងារនេះមានឈ្មោះថា: *"ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និង ទឹក"*។ ឈ្មោះនេះសរសេរជាពាក្យបំព្រួញថា "TWGAW"។

៩. មុខងារសំខាន់របស់ក្រុមការងារនេះ គឺជាអ្នកគាំទ្រ និងធ្វើសហការ នៅក្នុងការជួយដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យការងារអភិវឌ្ឍន៏វិស័យកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានការរីកចំរើនឡើង ។ យោងតាមតួនាទីនេះ ក្រុមការងារបច្ចេកទេសស្តីពីកសិកម្មនិងទឹកនេះ មានចំណងទាក់ទងជាមួយនឹងក្រុមការងារបច្ចេកទេសផ្សេងៗទៀត និង សំរបសំរួលកិច្ចពិភាក្សាកំរិតខ្ពស់លើគោលនយោបាយ ដោយផ្សារភ្ជាប់ទៅនឹងយន្តការ និង ដំណើរការកិច្ចពិភាក្សាទាំងឡាយដូចជា ផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចសង្គមលើកទី២ ឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០៣-២០០៥ និង គោលដៅអភិវឌ្ឍន៏សហស្សវត្សកម្ពុជា និងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ហើយនឹងកិច្ចពិភាក្សាណាមួយរបៀបនេះផ្សេងទៀត ។

១០. ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ ផ្តល់នូវយន្តការមួយថ្នាក់បច្ចេកទេស សំរាប់ការងារសំរបសំរួលរវាងរាជរដ្ឋាភិបាលនិងក្រុមប្រទេសផ្តល់ជំនួយ នៅក្នុងវិស័យកសិកម្មដែលរាប់បញ្ចូលទាំងការគ្រប់គ្រងធនធានទឹក។ ក្រុមការងារនេះនឹងមានគោលបំណងរកមើលអាទិភាពទាំងឡាយរបស់វិស័យ ធ្វើអោយសកម្មភាពទាំងឡាយមានភាព

ស៊ីសង្វាក់គ្នា កែលំអការប្រើប្រាស់និងការប្រមូលធនធានទាំងឡាយ និងគាំទ្រកិច្ចប្រឹងប្រែងនានាក្នុងការពង្រឹងសមត្ថភាពផ្នែកកសិកម្ម ដើម្បីរួមវិភាគទានដល់កំណើនសេដ្ឋកិច្ច និងបញ្ចូលប្រជាជនក្រីក្រទៅក្នុងដំណើរការនេះ ។

១១. នៅក្នុងន័យនេះ ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ ផ្តល់នូវចំណងទាក់ទងមួយរវាងកិច្ចពិភាក្សាថ្នាក់ខ្ពស់អំពីគោលនយោបាយ និងការអនុវត្តន៍ការងារនៅតាមកន្លែង/ការងារគំរោង ។ ក្រុមការងារនេះជួយប្រែក្លាយគោលដៅនានានៃគោលនយោបាយថ្នាក់ខ្ពស់ (*ដែលបានគូសបញ្ជាក់យ៉ាងច្បាស់លាស់ នៅក្នុងឯកសារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី ២ ឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០៣-២០០៥ យុទ្ធសាស្ត្រចតុកោណ និងឯកសារស្រដៀងគ្នានេះផ្សេងៗទៀត*) អោយក្លាយទៅជាកម្មវិធី និងគំរោងទាំងឡាយដែលទាក់ទងនឹងវិស័យ និងបញ្ច្រាសមកវិញ ជួយធានាអោយការកំណត់នូវគោលដៅនានានៃគោលនយោបាយអាចសំរេចបាន។ ការងារនេះនឹងជួយដល់អ្នកពាក់ព័ន្ធទាំងអស់អោយចូលរួមដោយពេញលេញ នៅក្នុងការពិភាក្សាគ្នាអំពីការងារអភិវឌ្ឍន៍ដែលទាក់ទងជាមួយនឹងវិស័យកសិកម្ម។

១២. នៅក្នុងបរិបទនៃក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ កសិកម្មរួមមាន ផលិតកម្ម ការកែឆ្នៃ និងការរកទីផ្សារសំរាប់ស្បៀងអាហារ និង ដំណាំឧស្សាហកម្ម ក៏ដូចជាបសុសត្វ និង បសុបក្សី ជាដើម ។ ការគ្រប់គ្រងធនធានទឹក ដែលទាក់ទងជាមួយនឹងវិស័យកសិកម្មនេះ គឺមានទំនាក់ទំនងសំខាន់ជាមួយនឹងការស្រោចស្រព ប៉ុន្តែជាគោលការណ៍ ក៏មានរាប់បញ្ចូលទាំងបច្ចេកទេសសន្សំសំចៃទឹក និងការប្រើប្រាស់ទឹកនៅក្នុងផលិតកម្មដំណាំឱ្យកាន់តែមានប្រសិទ្ធភាពឡើង។

១៣. ទោះបីជាមានកំរិតព្រំដែនសំរាប់វិស័យនេះក៏ដោយ គេយល់ឃើញថា ការអភិវឌ្ឍន៍វិស័យកសិកម្មមិនអាចកាត់ផ្តាច់ចេញពីបញ្ហាទាំងឡាយនៃការអភិវឌ្ឍន៍ជនបទយ៉ាងទូលំទូលាយនោះបានទេ ជាពិសេសប្រសិនបើវិស័យកសិកម្មត្រូវបានចាត់ទុកថាមានតួនាទីនាំមុខមួយនៅក្នុងកំណើនសេដ្ឋកិច្ច ដែលនឹងអាចសំរេចទៅបាន លុះណាតែគួបផ្សំគ្នាជាមួយនឹងការផ្លាស់ប្តូរយ៉ាងទូលំទូលាយខាងបច្ចេកទេស និងស្ថាប័នដែលនៅខាងក្រៅវិស័យកសិកម្ម។ ជាឧទាហរណ៍ការមានលទ្ធភាពទទួលបាននូវទីផ្សារ តាមរយៈនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមដែលមានភាពប្រសើរឡើង ក៏ដូចជារដ្ឋបាលមួយដែលមានប្រសិទ្ធភាព គឺជាកូនសោរដ៏សំខាន់ចំពោះអភិវឌ្ឍន៍វិស័យកសិកម្មមួយបែប ដែលបានគ្រោងទុកជាមុនដោយក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ ។ ហេតុដូច្នេះហើយ ក្រុមការងារនេះនឹងបំពេញមុខងារជាវេទិកាមួយដែលសំរបសំរួលការពិភាក្សាថ្នាក់អន្តរក្រសួង ស្តីពីបញ្ហាទាំងឡាយដែលទាក់ទងជាមួយនឹងកសិកម្មដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធមួយចំនួន ។

១៤. តែទោះជាយ៉ាងណា នៅក្នុងពេលជាមួយគ្នានេះដែរ ក្រុមការងារនេះនឹងមានការប្រយ័ត្នប្រយែងដោយមិនជំនួសភារកិច្ចពិតប្រាកដរបស់ក្រសួងនោះឡើយ ។ ការធ្វើផែនការគោលដៅ ការកំណត់នូវផ្នែកជាអាទិភាព និងការកំណត់សូចនាករទាំងឡាយ ក៏ដូចជាការអនុវត្តន៍ និងការតាមដានត្រួតពិនិត្យជាក់ស្តែង ជាគោលការណ៍គឺជា

កិច្ចការរបស់រាជរដ្ឋាភិបាល ដែលត្រូវបានគាំទ្រថាជាវិធានការរួមមួយដោយក្រុមប្រទេសផ្តល់ជំនួយ ។ ជាទ្រឹស្តី ក្រសួងពាក់ព័ន្ធទាំងឡាយ គឺជាអ្នកដើរតួដ៏សំខាន់នៅក្នុងបរិបទនេះ។ ដោយសារតែមានចំណុចខ្សោយខាងស្ថាប័ន សេណារីយ៉ូនេះ នៅតែត្រូវការពេលវេលាមួយរយៈថែមទៀត ដើម្បីក្លាយទៅជាការពិត ហើយក្រុមប្រទេសផ្តល់ជំនួយ តាមរយៈក្រុមការងារបច្ចេកទេសទាំងឡាយជាទូទៅ និង ដោយឡែកតាមរយៈក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក នឹងជួយអោយបានសំរេចនូវបញ្ហានេះ។

## ៣ គោលបំណង និងមុខងារ

១៥. គោលបំណង និងគោលដៅរួមរបស់ក្រុមការងារនេះ គឺគាំទ្រ និងពង្រឹងការអភិវឌ្ឍនវិស័យកសិកម្ម ដើម្បីរួមវិភាគទានដល់កំណើនសេដ្ឋកិច្ច សន្តិសុខស្បៀងដែលមានភាពប្រសើរឡើង ការកើនឡើងនូវការងារ និងការកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងន័យនេះ គោលបំណង និងមុខងារដ៏ជាក់លាក់ទាំងឡាយខាងក្រោមនេះ នឹងត្រូវតែអនុវត្តន៏តាមៈ

### ១. ការចែករំលែកពត៌មានរវាងរដ្ឋាភិបាល និងក្រុមប្រទេសផ្តល់ជំនួយ

ក្រុមការងារបច្ចេកទេសស្តីពីកសិកម្មនិងទឹក គឺជាវេទិកាមួយដែលសំរបសំរួលការផ្លាស់ប្តូរពតិមានគ្នាទៅវិញទៅមក អំពីសកម្មភាពទាំងឡាយនៅក្នុងវិស័យកសិកម្ម និងគ្រប់គ្រងទឹក ។ ទោះបីជាការចែករំលែកពតិមាន តាមរយៈនៃការធ្វើរបាយការណ៏ពីបេសកកម្មរួមគ្នា ការផ្លាស់ប្តូរឯកសារគំរោងទៅវិញទៅមក និងរូបភាពផ្សេងៗទៀតនៃការពិគ្រោះយោបល់គ្នាត្រូវបានអនុវត្តន៏ជាញឹកញាប់រួចហើយក៏ដោយ ក៏ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក នឹងផ្តល់នូវវេទិកាមួយសំរាប់ដំណើរការនេះ ជាមួយនឹងតំលៃបន្ថែមនៃការផ្សារភ្ជាប់ទៅនឹងការពិភាក្សាយ៉ាងទូលំទូលាយមួយអំពីគោលនយោបាយ ។ ការធ្វើយ៉ាងនេះនឹងធ្វើឱ្យការចែករំលែកពតិមាននេះមានប្រសិទ្ធភាព កាន់តែប្រសើរឡើងថែមទៀត ។ ឧបករណ៏នានាដូចជា មូលដ្ឋានទិន្នន័យសកម្មភាពរបស់ក្រុមប្រទេសផ្តល់ជំនួយ ដែលទើបនឹងចងក្រងរួចនាពេលថ្មីៗនេះ គឺមានសារៈប្រយោជន៏ក្នុងការគាំទ្រដល់ដំណើរការជាទម្លាប់ធម្មតាមួយនៃការចែករំលែកពតិមាននេះ ។ ដោយការប្រើជាមូលដ្ឋាននូវឧទាហរណ៏ជាក់ស្តែងបែបនេះ ជំហានជាបន្តបន្ទាប់អាចត្រូវបានអនុវត្ត ទៅតាមតំរូវការ និងភាពដែលអាចធ្វើទៅបាន ដោយរាប់បញ្ចូលទាំងការគាំទ្រចំពោះវេទិកាផ្លាស់ប្តូរពតិមានដែលគ្របដណ្តប់ទូទាំងវិស័យទៅតាមខ្សែបណ្តាញនៃគំរោងសាកល្បងទាំងឡាយដូចជាមជ្ឈមណ្ឌលឯកសារ និងពតិមាន កសិកម្ម និងគេហទំព័ររបស់មជ្ឈមណ្ឌលនោះជាដើម ។

ការចែករំលែកពតិមាននេះ បង្កើតនូវតម្លាភាព និងជាមូលដ្ឋានគ្រឹះ សំរាប់ការដោះស្រាយដោយជោគជ័យនូវរាល់គោលបំណង និងមុខងារដទៃទៀតជាបន្តបន្ទាប់ ។

## ២. ការអភិវឌ្ឍន៍ និងការកំណត់អាទិភាពគោលនយោបាយសំរាប់វិស័យ

ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ គាំទ្រការធ្វើផែនការវិស័យរយៈពេលមធ្យម និងរយៈពេលវែង និងការកំណត់អាទិភាពនូវសកម្មភាពទាំងឡាយ ឱ្យស្របទៅតាមការពិភាក្សាអំពីគោលនយោបាយយ៉ាងទូលំទូលាយ ដូចបានគូសបញ្ជាក់យ៉ាងច្បាស់លាស់ ជាឧទាហរណ៍ នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី ២ ឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ ២០០៣-២០០៥ និងយុទ្ធសាស្ត្រចតុកោណ ។ ការធ្វើដូច្នេះ នឹងជួយសំរបសំរួលសកម្មភាពនៅក្នុងវិស័យ និងជំរុញអោយការប្រើប្រាស់ប្រភពធនធានដ៏ស្តួចស្តើងឱ្យកាន់តែមានប្រសិទ្ធភាព ដោយការចាត់ចែងប្រភពធនធានទាំងនោះឱ្យត្រូវទៅតាមផ្នែកជាអាទិភាពទាំងឡាយដែលបានព្រមព្រៀងគ្នា ។ ត្រូវមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីកំណត់អំពីធាតុសំខាន់ៗជាស្នូលនៃគោលនយោបាយគ្រប់គ្រងការងារកសិកម្ម និង ធនធានទឹក សំរាប់រយៈពេលពី ៥ ទៅ ១០ឆ្នាំខាងមុខ ដែលនៅក្នុងនោះរួមមានៈ ១) ផ្នែកឯកជន និងទីផ្សារនឹងដើរតួនាទីមួយយ៉ាងសំខាន់។ ២) ផលិតករតូចតាច និងទ្រង់ទ្រាយបន្ទាប់បន្សំ មានឱកាសដើម្បីចូលរួម។ ៣) ប្រភពធានធានទាំងឡាយត្រូវបានប្រើប្រាស់តាមវិធីមួយប្រកបដោយនិរន្តរភាព និង ៤) ស្ថាប័ននានារបស់រដ្ឋាភិបាលមានប្រសិទ្ធភាពនៅក្នុងការផ្តល់សេវាទាំងឡាយ និងដើរតួនាទីរបស់ខ្លួននៅក្នុងការបង្កើត និង ថែរក្សាឱ្យបាននូវ " *បរិយាកាសដ៏អនុគ្រោះមួយ* " ។

## ៣. ការលើកកំពស់វិធីសាស្ត្រអភិវឌ្ឍន៍គ្របដណ្តប់ទូទាំងវិស័យមួយ

ក្រុមការងារនេះនឹងលើកកំពស់វិធីសាស្ត្រអភិវឌ្ឍន៍គ្របដណ្តប់វិស័យទាំងមូលមួយ (sector-wide development approach) ដោយផ្អែកទៅលើគោលនយោបាយសំរាប់វិស័យដែលបានព្រមព្រៀងគ្នា ក៏ដូចជានីតិវិធីរដ្ឋបាល និង ប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និង តម្លាភាពនៅក្នុងបរិបទនៃវិមជ្ឈការរដ្ឋបាលនិងការធ្វើផែនការដែលទាក់ទងទៅនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ( *សូមពិនិត្យមើលគោលបំណងទី ៥* ) ។

## ៤. ការសំរបសំរួល

ដោយធ្វើជាវេទិកាមួយសំរាប់ចែករំលែកពតិមាន និងពិភាក្សាអំពីគោលនយោបាយសំរាប់វិស័យ ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ អាចធ្វើការកំណត់ពីការផ្សារភ្ជាប់ និងការបំពេញឱ្យគ្នាទៅវិញទៅមករវាងសកម្មភាពទាំងឡាយរបស់ក្រុមប្រទេសផ្តល់ជំនួយ និងជួយសំរបសំរួលការបែងចែកប្រភពធនធានទាំងឡាយ។ ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក ជំរុញអោយមានការពិនិត្យមើលឡើងវិញរួមគ្នា និងការសិក្សាអំពីបញ្ហាជាក់លាក់ (thematic studies) ដើម្បីធ្វើអោយដំណើរការអភិវឌ្ឍន៍គោលនយោបាយមានភាពប្រសើរឡើង។ ឧទាហរណ៍ផ្នែកមួយដែលស័ក្តិសមឱ្យមានការសិក្សារួមគ្នា ក៏ដូចជាការសំរបសំរួលរវាងសកម្មភាពទាំងឡាយរបស់គំរោង ហើយរហូតដល់រវាងវិស័យនានាផងនោះ គឺសមាជិកភាពរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដែលបង្កើតឡើងនូវល័ក្ខខ័ណ្ឌក្របខ័ណ្ឌថ្មីៗសំរាប់វិស័យកសិកម្ម។ ឧទាហរណ៍មួយផ្សេងទៀត ដែលក្រុមការងារនេះ គួរតែបង្កើនការងារសំរបសំរួលឱ្យទៅមុខនោះ គឺការធ្វើសមាហរណកម្មការងារផ្សព្វផ្សាយកសិកម្ម និងការងារគ្រប់គ្រងទឹក និង

ការងារធារាសាស្ត្រ ដើម្បីលើកកំពស់ការិតជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់គ្រួសារប្រជាកសិករ និងទាញយកផលប្រយោជន៍ពីការលើកកំពស់ផលិតភាព ដើម្បីធានាឱ្យមាននិរន្តរភាពខាងសេដ្ឋកិច្ចនៃគំរោងស្រោចស្រពទាំងឡាយ ។

**៥. ការលើកឡើងអំពីផ្នែករួមគ្នាដែលទាក់ទងជាមួយនឹងបញ្ហាបច្ចេកទេស និងរដ្ឋបាល**

មានតំរូវការមួយដើម្បីបំភ្លឺ និងពង្រឹងតួនាទី និងមុខងាររបស់ស្ថាប័នទាំងឡាយ ដែលទាក់ទងជាមួយនឹងវិស័យ។ ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងកំណែទំរង់វិស័យ នឹងតំរូវឱ្យស្ថាប័នទាំងឡាយអាចធ្វើអន្តរកម្មនៅក្នុងរង្វង់ស្ថាប័ន និងរវាងស្ថាប័នផ្សេងៗគ្នានៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ។ ផ្នែកពិសេសៗដែលមានផលប្រយោជន៍រួមគ្នា ហើយដែលនឹងត្រូវលើកឡើងដោយក្រុមការងារបច្ចេកទេសស្តីពីកសិកម្មនិងទឹក រួមមាន ការគ្រោងរៀបចំ និងសាកល្បងសេណារីយ៉ូនៃការផ្តល់មូលនិធិ ដើម្បីពុះពារដោះស្រាយគោលនយោបាយផ្សេងៗនៃការឧបត្ថម្ភបន្ថែមទៅលើប្រាក់បៀវត្សរ៍ និងការអនុវត្តន៍យន្តការប្រកបដោយប្រសិទ្ធភាពក្នុងការតាមដានត្រួតពិនិត្យនិងវាយតំលៃ ឧទាហរណ៍ ដោយដាក់ឱ្យអនុវត្តស្តង់ដាររួមដែលបានព្រមព្រៀងគ្នារួចហើយសំរាប់ការតាមដានត្រួតពិនិត្យនិងវាយតំលៃ។ នៅក្នុងការលើកឡើងអំពីបញ្ហាទាំងនេះ ក្រុមការងារនេះនឹងជំរុញដំណើរការវិមជ្ឈការ/វិសហមជ្ឈការរដ្ឋបាល និងការអនុម័តការធ្វើផែនការ និងគំរោងថវិកាដែលទាក់ទងនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម។

**៦. ការសំរបសំរួលយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម គោលដៅអភិវឌ្ឍន៍សហស្សវត្ស យុទ្ធសាស្ត្រចតុកោណ និង កិច្ចប្រជុំក្រុមពិគ្រោះយោបល់ និងការពិភាក្សាអំពីគោលនយោបាយ**

នៅក្នុងបរិបទនៃការពិភាក្សាអំពីគោលនយោបាយខាងលើនេះ ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក នឹងជួយកំណត់ និងធ្វើរបាយការណ៍អំពីគោលបំណងដែលពាក់ព័ន្ធ ការិតគោល និងសូចនាករទាំងឡាយ ដើម្បីតាមដានត្រួតពិនិត្យមើលការរីកចំរើននៃកំណែទំរង់ ។ ក្រុមការងារនេះ គាំទ្រដល់ការពិភាក្សាការិតខ្ពស់លើគោលនយោបាយ ដោយសំរបសំរួលការផ្តោតការយកចិត្តទុកដាក់ប្រកបដោយតុល្យភាពមួយលើវិស័យកសិកម្ម ដែលឆ្លុះបញ្ចាំងអំពីសារៈសំខាន់យ៉ាងទូលំទូលាយខាងសេដ្ឋកិច្ចរបស់វិស័យនេះ និងមានការគ្រប់គ្រងធនធានធម្មជាតិ ក៏ដូចជាបញ្ហាទាំងឡាយនៃសេដ្ឋកិច្ចសង្គម ។ ជាពិសេស ក្រុមការងារនេះនឹងរួមវិភាគទានដល់ការងាររៀបចំដាក់បញ្ចូលគ្នានូវឯកសារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទី៣ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រលើកទី២ ដែលបានគ្រោងទុកដោយរាជរដ្ឋាភិបាលសំរាប់ឆ្នាំ ២០០៥ ។

## ៤ អង្គការចាត់តាំង និងប្រតិបត្តិការ

១៦. បរិយាកាសអភិវឌ្ឍន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ថាមានលក្ខណៈប្រកបដោយថាមពល។ ហេតុដូចនេះ វិធីសាស្ត្រប្រតិបត្តិការរបស់ក្រុមការងារនេះនឹងមានលក្ខណៈជាក់ស្តែង និងអាចបត់បែនបាន ដើម្បីអោយស្របគ្នាទៅនឹងស្ថានភាពផ្លាស់ប្តូរនេះ។

ក្រុមការងារនេះនឹងបំរើជាយន្តការមួយសំរាប់ការពិភាក្សាដែលធ្វើជាបន្តបន្ទាប់ ការសំរបសំរួល ការកំណត់បញ្ហា និងការធ្វើផែនការសំរាប់វិស័យ ដូចដែលបានគូសបញ្ជាក់នៅខាងលើ ។ ជាប្រការសំខាន់ក្នុងការរក្សាបន្ទុកការងាររបស់ក្រុមការងារនេះឱ្យនៅត្រឹមកំរិតមួយដែលអាចគ្រប់គ្រងបាន ហើយឱ្យអាទិភាពលើសកម្មភាពទាំងឡាយអោយស្របទៅតាមនោះ ។

## ៤.១ សមាជិកភាព

សមាជិកភាព មានលក្ខណៈសេរី ។ សមាជិកទាំងឡាយ មានសមាសភាពមកពីស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល និងបណ្តាអង្គការរបស់ក្រុមប្រទេសផ្តល់ជំនួយ ដែលបានសំដែងការចាប់អារម្មណ៍របស់ខ្លួន នៅក្នុងក្រុមការងារនេះ:

**ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា:** *(ដែលបានស្នើឡើង)*

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**បណ្តាអង្គការរបស់ក្រុមប្រទេសផ្តល់ជំនួយ:**

- មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មអន្តរជាតិអូស្ត្រាលី (ACIAR)
- មូលនិធិអន្តរជាតិ សំរាប់អភិវឌ្ឍន៍កសិកម្ម (IFAD)
- កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- អង្គការម្ហូបអាហារ និងកសិកម្ម (FAO)
- កម្មវិធីស្បៀងអាហារពិភពលោក (WFP)
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- ធនាគារពិភពលោក (WB)

- សហគមន៍អឺរ៉ុប (EC)
- ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID)
- នាយកដ្ឋានសំរាប់អភិវឌ្ឍន៍អន្តរជាតិ (DFID)
- អង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសជីធីហ្សិតរបស់ប្រទេសអាល្លឺម៉ង់ (GTZ)
- ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ជប៉ុន (JICA)
- ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ដាណឺម៉ាក (DANIDA)
- ទីភ្នាក់ងារអភិវឌ្ឍន៍ បារាំង (AFD)
- អង្គការកិច្ចសហប្រតិបត្តិការ បារាំង (French Cooperation)
- ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ នូវែលហ្សេឡង់ (NZAID)
- ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ កាណាដា (CIDA)

ដោយផ្អែកទៅលើមតិឯកភាពគ្នាក្នុងក្រុម ក្រុមការងារនេះអាចទទួលសមាជិកថ្មីៗទៀតនៅពេលណាក៏បានដែរ ។

១៨. ក្រុមអ្នកតំណាងនៃស្ថាប័នផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល អាចត្រូវបានអញ្ជើញនៅក្នុងពេលណាក៏បាន ដើម្បីធ្វើជាអ្នកសង្កេតការណ៍ ឬជាភ្ញៀវកិត្តិយស ។ នេះគឺជាយន្តការមួយដែលអាចបត់បែនបាននៅក្នុងការគាំទ្រការផ្លាស់ប្តូរពតិមានជាមួយនឹងបណ្តាក្រសួងទាំងឡាយ ស្ថាប័នសំរាប់សំរបសំរួលការងារទាំងឡាយរបស់រាជរដ្ឋាភិបាល (*ឧ. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល (CAR)*) និងបណ្តាស្ថាប័នស្រាវជ្រាវ (*ឧ. វិទ្យាស្ថានជាតិគ្រប់គ្រង*) ។ ក្រសួងទាំងឡាយដែលមានទំនាក់ទំនងដោយផ្អែកលើប្រធានបទជិតស្និទ្ធនឹងក្រុមការងារនេះមាន : ឧទាហរណ៍ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងបរិស្ថាន ។ ដោយផ្អែកទៅលើគោលការណ៍ដូចគ្នានេះ ក្រុមតំណាងសង្គមស៊ីវិល វិស័យឯកជន និងបណ្តាអង្គការផ្សេងៗទៀត អាចត្រូវបានអញ្ជើញអោយមកចូលរួមក្នុងកិច្ចប្រជុំ និងចូលរួមនៅក្នុងការងាររបស់ក្រុមការងារនេះ ។ បណ្តាអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងធ្វើការងារនៅក្នុងវិស័យកសិកម្ម និងគ្រប់គ្រងធនធានទឹក នឹងត្រូវបានអញ្ជើញអោយតែងតាំងអង្គការចំនួន ២ ឬ ៣ មកចូលរួមនៅក្នុងក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ ដើម្បីធ្វើជាសមាជិកអចិន្ត្រៃយ៍តំណាងសហគមន៍អង្គការក្រៅរដ្ឋាភិបាល ។

## **៤.២ អធិបតី**

១៩. ក្រុមការងារនេះដឹកនាំដោយសហប្រធានចំនួនពីររូប ដែលកាន់កាប់ដោយតំណាងម្នាក់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាងម្នាក់ទៀតមកពីក្រសួងធនធានទឹកនិងឧតុនិយម ។ នេះឆ្លុះបញ្ចាំងអំពីសារៈសំខាន់នៃវិស័យទាំងពីរដែលក្រុមការងារនេះត្រូវដោះស្រាយៈ កសិកម្ម និងការងារគ្រប់គ្រងធនធានទឹកនិងធារាសាស្ត្រ ។ អ្នកដែលកាន់កាប់មុខតំណែងជាសហប្រធាននេះ ត្រូវបានតែងតាំងដោយសាមីក្រសួងរៀងខ្លួន ។

២០. សហអនុប្រធានពីររូប ដែលមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ក៏ត្រូវបានតែងតាំងដោយសាម៉ីក្រសួងរៀងខ្លួនផងដែរ ។ សហអនុប្រធានទាំងពីររូបនេះ ទទួលរ៉ាប់រងភារកិច្ចរបស់សហប្រធាន នៅពេលដែលសហប្រធានទាំងពីររូបនោះអវត្តមាន ។

២១. សហអ្នកសំរបសំរួលដែលមកពីក្រុមប្រទេសផ្តល់ជំនួយពីររូប ជាតំណាងអោយក្រុមប្រទេសផ្តល់ជំនួយ និងជួយសហប្រធានទាំងពីររូបនោះ ។ សហអ្នកសំរបសំរួលទាំងពីររូបនេះ ត្រូវបានកំណត់ដោយការបោះឆ្នោតដោយក្រុមប្រទេសផ្តល់ជំនួយតាមរយៈ *(មតិភាគច្រើន)* ។ ក្រុមប្រទេសផ្តល់ជំនួយអាចធ្វើការបោះឆ្នោតជ្រើសតាំងមុខតំណែងនេះនៅពេលណាក៏បាន ។

២២. សហប្រធានទាំងពីររូបនេះ មានអាណត្តិក្នុងការបន្តអនុវត្តគោលបំណងទាំងឡាយដែលបានលើកឡើងខាងលើនេះ ។ ជាពិសេសសហប្រធានទាំងពីររូបនេះទទួលខុសត្រូវទៅលើការរៀបចំកិច្ចប្រជុំ និងអញ្ជើញសមាជិកទាំងអស់អោយមកចូលរួមក្នុងកិច្ចប្រជុំនេះ ។ សហប្រធានទាំងពីររូបនេះដឹកនាំអង្គប្រជុំ និងធានាថាកំណត់ហេតុនៃកិច្ចប្រជុំនេះត្រូវបានធ្វើឡើង ហើយចែកជូនគ្រប់សមាជិកនិងអ្នកចូលរួមទាំងអស់ ។ សហប្រធានទាំងពីររូបនេះត្រូវធានាអោយមានការភ្ជាប់នៃការប្រាស្រ័យទាក់ទងមួយប្រកបដោយប្រសិទ្ធភាពរវាងក្រុមការងារនេះ និង សាម៉ីក្រសួងរៀងខ្លួន ។

២៣. សហអ្នកសំរបសំរួលក្រុមប្រទេសផ្តល់ជំនួយទាំងពីររូប ផ្តល់ការគាំទ្រដល់សហប្រធានទាំងពីររូបនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។ លើសពីនេះទៅទៀត ពួកគេត្រូវធានាថា កិច្ចពិភាក្សា និងការសំរេចទាំងឡាយរបស់ក្រុមការងារនេះ ត្រូវបានជំរាបជូនទៅការពិភាក្សាថ្នាក់ខ្ពស់រវាងរាជរដ្ឋាភិបាល និងក្រុមប្រទេសផ្តល់ជំនួយ ដូចជាកិច្ចប្រជុំក្រុមពិគ្រោះយោបល់ជាដើម ។

២៤. សហប្រធានទាំងពីររូប និងសហអ្នកសំរបសំរួលទាំងពីររូបនេះ ត្រូវធានាថាផែនការការងារមួយត្រូវបានរៀបចំឡើង និងព្រមព្រៀងគ្នាដោយក្រុមការងារនេះ ។ ផែនការការងារទី១ នឹងត្រូវពិភាក្សាគ្នាភ្លាម នៅពេលដែលក្រុមការងារនេះត្រូវបានបង្កើតឡើង ។ ផែនការការងារនេះ ត្រូវបញ្ជាក់អំពីភារកិច្ច ពេលវេលា និងការទទួល ខុសត្រូវនានា ។ ជាពិសេសនៅពេលដំបូង សកម្មភាពទាំងឡាយជាមួយនឹងលទ្ធផលរំពឹងទុកជាក់ស្តែងពីដំបូងៗ នឹងត្រូវបានដាក់ជាអាទិភាព ។

### ៤.៣ លេខាធិការដ្ឋាន

២៥. ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ នឹងត្រូវបានគាំទ្រដោយលេខាធិការដ្ឋានមួយ និងទទួលមូលនិធិពីរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាអង្គការរបស់ប្រទេសផ្តល់ជំនួយ ។ ការរៀបរាប់លំអិតអំពីភារកិច្ច ( *ឧ. ក្របខ័ណ្ឌ*

*សមត្ថកិច្ច)* ចំនួន និងកំរិតថ្នាក់របស់មន្ត្រីនៃលេខាធិការដ្ឋាននេះ ( *រាប់ទាំងឯកសាររៀបរាប់ពីការងារដែលត្រូវបំពេញ)* ការបង្កើតរចនាសម្ព័ន្ធការិយាល័យ និងការផ្តល់មូលនិធិ តំរូវអោយមានការពិភាក្សាគ្នាជាបន្ថែមទៀត ។

### ៤.៤ អនុក្រុមទទួលបន្ទុកបញ្ហាជាក់លាក់

២៦. ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ អាចកំណត់អនុក្រុមទាំងឡាយដើម្បីលើកឡើងនូវគោលបញ្ហា និងបញ្ហាជាក់លាក់នានាឱ្យកាន់តែលំអិតថែមទៀត និងសំរបសំរួលការពិភាក្សាក្នុងក្រុមអោយបានស៊ីជំរៅ ។ សមាជិកអង្គការផ្សេងៗទៀត អាចត្រូវបានអញ្ជើញអោយមកចូលរួមនៅក្នុងអនុក្រុមនេះតាមតំរូវការ ។ អនុក្រុមនេះគឺជាយន្តការមួយដ៏សំខាន់ នៅក្នុងការផ្សារភ្ជាប់ជាមួយនឹងការពិភាក្សាផ្សេងៗទៀត ( *សូមពិនិត្យមើលចំណុច ៤.៦)* ។

### ៤.៥ កិច្ចប្រជុំ

២៧. កិច្ចប្រជុំទាំងឡាយ នឹងត្រូវបានអញ្ជើញដោយមានរបៀបវារៈនិងការធ្វើកំណត់ហេតុ ។ យ៉ាងហោចណាស់កិច្ចប្រជុំចំនួន ៦ *(ប្រាំមួយ)*ដង នឹងត្រូវធ្វើឡើងក្នុងរយៈពេលមួយឆ្នាំ ។

### ៤.៦ ទំនាក់ទំនងជាមួយនឹងក្រុមការងារផ្សេងៗទៀត កិច្ចប្រជុំក្រុមពិគ្រោះយោបល់ និងការពិភាក្សាអំពីគោលនយោបាយផ្សេងៗទៀត

២៨. ការពិភាក្សាថ្នាក់ខ្ពស់អំពីគោលនយោបាយ ដែលបានលើកឡើងនៅក្នុងផ្នែកទី ១ ផ្តល់នូវវេទិកានានា សំរាប់ការសំរបសំរួលកិច្ចខិតខំប្រឹងប្រែងទាំងឡាយរបស់ក្រុមប្រទេសផ្តល់ជំនួយ ជាមួយនឹងផែនការនានារបស់រាជរដ្ឋាភិបាលកម្ពុជា ។ ហេតុដូច្នេះហើយ វាមានសារៈសំខាន់សំរាប់ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ ធ្វើការភ្ជាប់ភារកិច្ចនិងសកម្មភាពទាំងឡាយរបស់ខ្លួនជាមួយនឹងគោលដៅ (target) និងគោលការណ៍ទាំងឡាយដែលបានគូសបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងឯកសារគោលនយោបាយផ្សេងៗរៀងខ្លួន និង ដើម្បីរួមចំណែកដល់ការកែប្រែគោលនយោបាយទាំងនោះឱ្យទាន់សភាពការណ៍តាមរបៀបមួយដែលឆ្លុះបញ្ចាំងនូវផ្នែកដ៏ទូលំទូលាយនៃកង្វល់ក្នុងវិស័យ ( *សូមពិនិត្យមើលគោលបំណងទី ៦ នៅក្នុងផ្នែកទី ៤)* ។ ក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ អាចដើរតួនាទីមួយយ៉ាងសំខាន់នៅក្នុងការធ្វើអោយការពិភាក្សាថ្នាក់ខ្ពស់អំពីគោលនយោបាយបានយល់ដឹង បានធ្វើជាម្ចាស់ និងត្រូវបានចូលរួមពីអ្នកដែលមានការពាក់ព័ន្ធទាំងអស់ និងនៅគ្រប់ជាន់ថ្នាក់ ។

២៩. យន្តការសំរបសំរួលមួយរវាងក្រុមការងារបច្ចេកទេសផ្សេងៗ និងរវាងក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹកនេះ និងកិច្ចប្រជុំក្រុមពិគ្រោះយោបល់គឺតំរូវអោយមាន ។ នៅពេលដែលសមាជិករាជរដ្ឋាភិបាលកម្ពុជា នៅក្នុងក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក ត្រូវបានស្នើសុំអោយផ្តល់ប្រឹក្សាទាក់ទងនឹងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ (ឬអំពីប្រធានបទណាមួយផ្សេងទៀត) ជូនរាជរដ្ឋាភិបាល អនុក្រុមមួយដែលមានសមាជិករាជរដ្ឋាភិបាលកម្ពុជា ដែលបានជ្រើសរើសយ៉ាងហោចណាស់ចំនួនបីរូបនឹងត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់សហប្រធានម្នាក់ សំរាប់គោលបំណងនេះ ។ នៅពេលដែលសមាជិកប្រទេសផ្តល់ជំនួយនៅក្នុងក្រុមការងារបច្ចេកទេសស្តីពីកសិកម្ម និងទឹក ត្រូវបាន

ស្នើសុំអោយផ្តល់ប្រឹក្សាដែលទាក់ទងជាមួយនឹងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ (ឬអំពីប្រធានបទណាមួយផ្សេងទៀត)ជូនសហគមន៍ប្រទេសផ្តល់ជំនួយ អនុក្រុមមួយដែលមានសមាជិកប្រទេសផ្តល់ជំនួយ ដែលបានជ្រើសរើសយ៉ាងហោចណាស់ចំនួនបីរូបនឹងត្រូវបានបង្កើតឡើង នៅក្រោមការដឹកនាំពីសហអ្នកសំរបសំរួល ប្រទេសផ្តល់ជំនួយម្នាក់សំរាប់គោលបំណងនេះ ។

៣០. ចំពោះដំណើរការពិគ្រោះយោបល់ផ្សេងៗទៀត អនុក្រុមមួយ ដែលមានសមាជិកយ៉ាងហោចណាស់ចំនួន បីរូប មកពីរាជរដ្ឋាភិបាលកម្ពុជា ឬពីប្រទេសផ្តល់ជំនួយ នឹងត្រូវបានជ្រើសរើសដោយក្រុមការងារនេះ ។

## ៤.៧ តារាងរចនាសម្ព័ន្ធ

ការពិភាក្សាទាំងឡាយខាងលើនេះ អាចត្រូវបានសង្ខេបនៅក្នុងដ្យាក្រាម ដូចខាងក្រោមនេះ (*សូមពិនិត្យមើលតារាងខាងក្រោមនេះ*) ។

